# ជីវិតរបស់សត្វផ្សោតទន្លេមេគង្គ

## មាតិការ


១. សេចក្តីផ្តើម.......................................................... ២

២. លក្ខណៈទូទៅរបស់សត្វផ្សោតទន្លេមេគង្គ.................................. ៣

៣. ការចិញ្ចឹមជីវិតរបស់សត្វផ្សោតទន្លេមេគង្គ................................ ៤

៤. ការបន្តពូជរបស់សត្វផ្សោតទន្លេមេគង្គ.................................... ៤

៥. លក្ខណៈពិសេសរបស់សត្វផ្សោតទន្លេមេគង្គ................................ ៥

៦. ភាពខុសគ្នារវាងសត្វផ្សោត និង ត្រី.......................................... ៦

៧. ការស្លាប់របស់សត្វផ្សោតទន្លេមេគង្គ...................................... ៧

៨. ការអភិរក្សសត្វផ្សោតទន្លេមេគង្គ.......................................... ៨

៩. ផែនការរៀបចំ និងការអភិរក្សធនធានសត្វផ្សោតទន្លេមេគង្គនៅក្នុង ខេត្តក្រចេះ ៩

៩. ១. ការបង្កើតគោលនយោបាយក្នុងការរៀបចំ និងអភិរក្សសត្វផ្សោតទន្លេមេគង្គ................៩-១០

១០. ការរៀបចំគំរោងផែនអោយមានភាពទាក់ទាញនៅតំបន់អន្លង់ផ្សោតកាំពី .១១

ផែនទីនៃភូមិកាំពី (ឧបសម្ព័ន្ធ នៃភូមិកាំពី)................................ ១២

១១. សេចក្តីសន្និដ្ឋាន.......................................................... ១៣

១២. អនុសាសន៍.......................................................... ១៤

១៣ ឯកសារស្រាវជ្រាវ ........................................ ១៥

# ជីវិតរបស់សត្វផ្សោតទន្លេមេគង្គ

## ១_សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលសំបូរទៅដោយភោគទ្រព្យវប្បធម៌ និងធម្មជាតិក្នុងខេត្តក្រុងនានាទូទាំងប្រទេស។ ប្រទេសកម្ពុជាដែលល្បីល្បាញ និងរីកសុះសាយខាងសម្បត្តិវប្បធម៌ ដូចជាប្រាង្គប្រាសាទអង្គរវត្តដែលបានរាប់បញ្ចូលជាសម្បត្តិបេតិកភណ្ឌទី៧នៅលើពិភពលោក និងបណ្តាប្រាង្គប្រាសាទនានាទៀតដែលមាននៅពាសពេញផ្ទៃប្រទេសកម្ពុជា។ ប៉ុន្តែ ប្រទេសកម្ពុជាក៏សំបូរទៅដោយសម្បត្តិធម្មជាតិដែលមិនចាញ់ប្រទេសនានាដែលនៅជុំវិញខ្លួនដែរ ព្រោះប្រទេសកម្ពុជាជាប្រទេសមួយដែលមានអំណោយផលពីធម្មជាតិ ហើយធម្មជាតិទាំងនោះមានលក្ខណៈ ធម្មជាតិពិតៗដោយគ្មានការកែច្នៃឡើយ។ តួយ៉ាងដូចជាតំបន់មួយដែលស្ថិតនៅក្នុងខេត្តក្រចេះដែលល្បីថាជាតំបន់អេកូទេសចរណ៍ (Eco-Tourism)ដែលមានលក្ខណៈជាធម្មជាតិពិតៗ ហើយព្រមទាំងមានការរស់នៅរបស់ថនិកសត្វមួយប្រភេទដែលយើងទាំងអស់គ្នាចង់ដឹងនឹងចង់ស្គាល់នោះ គឺជាប្រភេទសត្វផ្សោតទឹកសាបនៃទន្លេមេគង្គដែលស្ថិតនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែងនៃព្រះរាជាណាចក្រកម្ពុជា ។




ម្យ៉ាងទៀតប្រភេទសត្វផ្សោតទឹកសាបនេះ ដែលគេអោយឈ្មោះថា **សត្វផ្សោតទន្លេមេគង្គ (Mekong Dolphin Or Irawaddy Dolphin)** ដែលវាមានជំរករស់នៅក្នុងតំបន់កាំពីនៃខេត្តក្រចេះ។ ខេត្តក្រចេះក៏ជាតំបន់ទេសចរណ៍មួយដែលមានភាពទាក់ទាញជា ខ្លាំងពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ពីព្រោះទីនេះជាតំបន់ធម្មជាតិដែលមានពពួកថនិកសត្វផ្សោតរស់នៅ។ លើសពីនេះនៅតំបន់កាំពីក៏មានភូមិសាស្ត្រល្អអំណោយផលទាំងអាកាសធាតុ មច្ឆា សត្វផ្សោតទន្លេមេគង្គ និងតំបន់ទេសចរណ៍ជាច្រើនកន្លែងទៀត។ ម្យ៉ាងទៀតនៅតំបន់អន្លង់កាំពីនេះដែរនៅ រដូវប្រាំងយើងអាចមើលឃើញសំរស់របស់កោះជាច្រើននៅតាមដងទន្លេមេគង្គ និងការជិះទូកទស្សនាកំសាន្តមើលពីការរស់នៅរបស់សត្វផ្សោត និងជីវៈចំរុះជាច្រើនប្រភេទទៀតនៃខេត្តក្រចេះ។

## ២. លក្ខណៈទូទៅរបស់សត្វផ្សោតទន្លេមេគង្គ



សត្វផ្សោតទន្លេមេគង្គជាប្រភេទសត្វមួយដ៏កំរមួយនៅលើពិភពលោក ហើយសត្វផ្សោតប្រភេទទឹកសាបនេះមានរស់នៅតាមតំបន់អន្លង់នៃដងទន្លេមេគង្គភាគអាស៊ីអាគ្នេយ៏ ដូចជាប្រទេសកម្ពុជា និងប្រទេសឡាវ ។

ដោយឡែកនៅក្នុងប្រទេសកម្ពុជាសត្វផ្សោតប្រភេទទឹកសាបគឺមាននៅតែក្នុងតំបន់អន្លង់តាមដងទន្លេមេគង្គដែលស្ថិតនៅក្នុងទឹកដីខេត្តក្រចេះ និងខេត្តស្ទឹងត្រែងជាតំបន់ អេកូទេសចរណ៏ ( Eco-Tourism ) ព្រោះអនុគ្រោះដល់ការរស់នៅរបស់សត្វផ្សោតនេះ។ សត្វផ្សោតប្រភេទទឹកសាបនេះគេអោយឈ្មោះថា **សត្វផ្សោតទន្លេមេគង្គ (Mekong Dolphin)** ដោយយោងតាមការរស់នៅរបស់វាតាមដងទន្លេមេគង្គ ចំណែកឯប្រជាជននៅក្នុងតំបន់នេះបានដាក់ឈ្មោះរបស់សត្វផ្សោតនេះថា **សត្វផ្សោតក្បាលត្រឡោក** យាងទៅតាមការមើលឃើញរបស់ពួកគេថាសត្វផ្សោតនេះក្បាលរបស់វាដូចជា ត្រឡោកអញ្ចឹង ។

បច្ចុប្បន្នសត្វផ្សោតទន្លេមេគង្គនេះមានចំនួនតិចតួចបំផុតគឺប្រហែល ១៥០ក្បាលប៉ុណ្ណោះដោយគិតតាមតួលេខពីតំបន់អន្លង់ផ្សោតកាំពីស្ថិតក្នុងខេត្តក្រចេះ រហូតដល់ព្រំប្រទល់ប្រទេសឡាវ-កម្ពុជា (ខេត្តស្ទឹងត្រែង-ល្បាក់ខោន) ដែលមានអន្លង់សំរាប់សត្វផ្សោតរកស៊ី និងវាមានកន្លែងរស់នៅទាំងអស់ចំនួន ៩អន្លង់។ ខេត្តដែលសំបូរសត្វផ្សោតជាងគេនៅក្នុងប្រទេសកម្ពុជា គឺស្ថិតនៅក្នុងខេត្តក្រចេះ-ខេត្តស្ទឹងត្រែង ហើយតំបន់ដែលសំបូរសត្វផ្សោតជាងគេគឺតំបន់អន្លង់កាំពីដែលប្រជាជនរស់នៅក្នុងតំបន់នេះបានហៅថា **តំបន់អន្លង់ផ្សោតកាំពី** ព្រោះតំបន់អន្លង់មួយនេះមានសត្វផ្សោតប្រហែលពី ២៥ ដល់ ៣៥ ក្បាលឯណោះ គឺមានចំនួនសត្វផ្សោតរស់នៅច្រើនជាងតំបន់អន្លង់ដទៃទៀត។ សត្វផ្សោតទន្លេមេគង្គនេះការរស់នៅរបស់វា មានលក្ខណៈជាហ្វូង ឬជួនកាលមានលក្ខណៈតែឯងដោយវាធ្វើការហែលចល័តចុះឡើងតាមដងទន្លេមេគង្គ ពីព្រំប្រទល់ប្រទេសកម្ពុជាទៅដល់ព្រំប្រទល់ប្រទេសឡាវ ។ តំបន់ដែលវារស់នៅគឺតំបន់អន្លង់ដែលមានជំរៅ ទឹកជ្រៅៗជួនកាលវាអាចរស់នៅក្នុងជំរៅទឹករាក់ ១.៥ ម៉ែត្រ ហើយពេលខ្លះអាចធ្វើអោយវានឹងគើនខ្លួននៅលើច្រាំងដោយសារទឹករាក់ពេក។ សត្វផ្សោតមួយក្បាលអាចរស់បានរហូតដល់ទៅ ៦០-៧០ឆ្នាំ (រស់តាមលក្ខណៈធម្មជាតិរហូតដល់ពេលវាចាស់ស្លាប់) គឺមានទំងន់ចាប់ពី ១៧០-២៧០គីឡូ (នៅពេលដែលវាពេញវ័យរហូតដល់អាយុវាចាស់) ប្រវែងរបស់វាមាន ២.៧៥ ម៉ែត្រនៅពេលវាមានអាយុ ២៦ឆ្នាំ ហើយនៅរាល់១៥នាទីម្តងគឺវាងើបពីទឹកម្តងដើម្បីដកដង្ហើម ព្រោះវាមិនអាចសំងំទៅក្នុងទឹកបានយូរទេដោយគ្មានខ្យល់ដកដង្ហើមទេ។

## ៣. ការចិញ្ចឹមជីវិតរបស់សត្វផ្សោតទន្លេមេគង្គ



សត្វផ្សោតទន្លេមេគង្គ គឺជាថនិកសត្វចិញ្ចឹមជីវិតដោយការស៊ីត្រីជាអាហារ ( ស៊ីតែពាក់កណ្តាលខ្លួនចុះក្រោម) ហើយវាធ្វើការហែលរកចំណី ( ត្រី) នៅតាមតំបន់អន្លង់ ព្រោះតំបន់អន្លង់ជាតំបន់ដែលមានទឹកត្រជាក់ ហើយសំបូរត្រីជាងតំបន់នានានៅតាមដងទន្លេមេគង្គ ចាប់ពីតំបន់អន្លង់ផ្សោតកាំពីរហូតដល់ព្រំប្រទល់ប្រទេសឡាវ ។ គួបញ្ជាក់ដែលថា នៅរដូវទឹកឡើងគឺវាហែលរកស៊ីចល័តតាមអន្លង់នានា ហើយត្រឡប់មកកាន់កន្លែងដើមវិញនៅរដូវទឹកស្រក់ ព្រោះនៅរដូវទឹកឡើងមិនសូវសំបូរត្រីជាអាហាររបស់វាទេ ដូច្នេះវាត្រូវហែលចុះឡើងដើម្បីស្វែងរកចំណីរបស់វា ( ត្រី) ។

## ៤. ការបន្តពូជរបស់សត្វផ្សោតទន្លេមេគង្គ



សត្វផ្សោត គឺជាថនិកសត្វមួយប្រភេទដែលរស់នៅក្នុងទឹកសាបដ៏កំរមាននៅលើពិភពលោកយើងនេះ ហើយសត្វផ្សោតប្រភេទនេះក៏ជិតដាច់ពូជទៅ ហើយនៅសល់ប្រហែល ១៥០ ក្បាលប៉ុណ្ណោះដែលមាននៅតាមតំបន់អន្លង់តាមដងទន្លេមេគង្គ ( ពីតំបន់អន្លង់ផ្សោតប្រទេសកម្ពុជាស្ថិតក្នុងខេត្តក្រចេះទៅដល់តំបន់អន្លង់ផ្សោតព្រំប្រទល់ប្រទេសឡាវ) ។ អាយុរបស់ផ្សោតដែលអាចបន្តពូជបានគឺចាប់ពី ៧-៩ឆ្នាំ ឡើងទៅការបន្តពូជរបស់វា គឺស្ថិតនៅក្នុងតំបន់ដែលមានទឹករាក់ៗ ព្រោះងាយស្រួលក្នុងការដកដង្ហើម ( មានគ្នាវាជួយដោលអោយដកដង្ហើមផងដែរ) ហើយការបន្តពូជរបស់សត្វផ្សោតគឺ ២-៣ឆ្នាំមានកូនមួយ ( យោងតាមការស្រាវជ្រាវរបស់ក្រុមអ្នកវិទ្យាសាស្រ្ត) កូនផ្សោតដែលកើតមកមានទំងន់ពី ៨-១២គីឡូ ។ សត្វផ្សោតការបង្កកំណើតរបស់វា គឺដូចជាមនុស្សដែរចំណែកឯការចិញ្ចឹមកូនរបស់វាក៏ដូចជាមនុស្សដែរ គឺវាចិញ្ចឹមកូនដោយទឹកដោះ ។ ក្រោយពីការកើតកូនបានមួយអាទិត្យ គឺវាបណ្តើរកូនរបស់វារហូតដល់អាយុ១ឆ្នាំ ហើយក្រោយពីកូនផ្សោតចាប់ពីអាយុ១ឆ្នាំឡើងទៅមេរបស់វាឈប់អោយ បៅដោះដោយអោយកូនរបស់វាធ្វើការហែលរកចំណី ( ត្រី) ដោយខ្លួនឯង ( ប៉ុន្តែ មេនិងកូនផ្សោតគឺនៅតែ រស់នៅជាមួយគ្នា) ។

## ៥. លក្ខណៈពិសេសរបស់សត្វផ្សោតទន្លេមេគង្គ




ដងខ្លួនមានប្រវែង ២.៧៥ម នៅពេលដែលវាមានអាយុ ២៦ឆ្នាំ

សត្វផ្សោត ជាថនិកសត្វដែលមានលក្ខណៈពិសេសជាងពពួកសត្វដទៃទៀត ព្រោះខ្លួនរបស់វាអាចប្រែប្រួលពណ៌សម្បុររបស់ទៅតាមទឹកទន្លេ (នៅរដូវទឹកឡើង គឺមានពណ៌សនិងនៅរដូវទឹកសំរក គឺមាន ពណ៌ប្រផេះ) ហើយយើងមិនអាចធ្វើការកំណត់ពណ៌របស់វាអោយប្រាកដកច្បាស់លាស់នោះទេ គឺវាប្រែប្រួលពណ៌រហូត។ លក្ខណៈពិសេសម៉្យាងទៀត គឺសត្វផ្សោតទន្លេមេគង្គនេះក្នុងខ្លួនរបស់វាបែងចែកខួរក្បាលជា ២ចំណែក សំរាប់ធ្វើការផ្លាស់ប្តូរចលនានៅពេលដែលវាសំរាក (ដេក) គឺម្ខាងធ្វើចលនា និងម្ខាងទៀតសំរាកតែវាផ្លាស់ប្តូរចលនាគ្នាជានិច្ចមិនថាយប់ឬថ្ងៃឡើយ (យោងតាមការស្រាវជ្រាវរបស់ក្រុមអ្នកវិទ្យាសាស្ត្រ)។

ចំណែកឯភាពវៃឆ្លាតរបស់សត្វផ្សោតក្បាលត្រឡោកនេះក៏មិនចាញ់សត្វផ្សោតសមុទ្រដែរ ដោយយោងតាមការស្រាវជ្រាវរបស់អ្នកអភិរក្សសត្វនៅប្រទេសជប៉ុន បានយកសត្វផ្សោតក្បាលត្រឡោកទន្លេមេគង្គនេះចំនួន ២ក្បាលទៅបង្ហាត់ជាមួយសត្វផ្សោតសមុទ្រលទ្ធផល គឺសត្វផ្សោតក្បាលត្រឡោកនេះអាចបង្ហាត់បានដូចគ្នាទៅនឹងសត្វផ្សោតសមុទ្រដែរ ហើយភាពវៃឆ្លាតរបស់វាគឺដូចគ្នា។

## ៦. ភាពខុសគ្នារវាងសត្វផ្សោត និង ត្រី

មានការយល់ច្រលំពីសំណាក់ប្រជាជនយើងមួយចំនួនដែលបានគិតថាសត្វផ្សោត គឺជាប្រភេទត្រីដ៏ធំមួយ ។ សត្វផ្សោតទន្លេមេគង្គ (Irawaddy dolphin) មិនមែនជាប្រភេទត្រីទេ ហើយវាក៏ត្រូវការខ្យល់សំរាប់ដកដង្ហើម ដូចជាមនុស្ស និងពពួកសត្វចតុបាតដទៃទៀតដែរ ។

សត្វផ្សោត និង ត្រី មានលក្ខណ:ខុសគ្នាដូចជា:

| សត្វផ្សោត | ត្រី |
|---|---|
| មានព្រុយនៅលើមុខរបស់ពួកវា | មិនមានព្រុយលើមុខទេ-មានតែស្រកានៅដងខ្លួនរបស់វា |
| ខ្លួនរបស់វាមានកំដៅ និង មានឈាម | ខ្លួនរបស់វាត្រជាក់ និង មានឈាម |
| សត្វផ្សោតផ្តល់កំនើតអោយកូនរបស់វា ដូចជាកូនមនុស្សដែរ (ពេលកើតគឺចេញកន្ទុយមកមុន) ហើយចិញ្ចឹមកូនដោយទឹកដោះ | ត្រីផ្តល់កំណើតអោយកូនរបស់វាជាពង ហើយចិញ្ចឹមកូនដោយស៊ីរុក្ខជាតិ និង សត្វល្អិតតូចៗ |
| កូនរបស់សត្វផ្សោតមិនអាចរស់នៅដោយគ្មានមេរបស់វាទេ ក្នុងរយ:ពេលយ៉ាងហោចណាស់ក៏មួយឆ្នាំដែរ | កូនត្រីអាចរស់នៅដោយខ្លួនឯងបាន និងមិនចាំបាច់មានមេថែរក្សាឡើយ |
| មានសួត សំរាប់ធ្វើការដកដង្ហើមតាមប្រហោងស្រមុក | វាមិនត្រូវការងើបដកដង្ហើមយកខ្យល់ទេ ប៉ុន្តែវាត្រូវការអុកស៊ីសែនពីក្នុងទឹក |
| កន្ទុយរបស់វារាងផ្តេក ហើយធ្វើចលនាបកចុះ-ឡើង | កន្ទុយរបស់វារាងបញ្ឈរ ហើយធ្វើចលនាបកឆ្វេង-ស្តាំ |

## ៧. ការស្លាប់របស់សត្វផ្សោតទន្លេមេគង្គ



អត្រានៃការស្លាប់របស់សត្វផ្សោតបណ្តាលមកពីកត្តាពីរយ៉ាង គឺកត្តាមនុស្ស និងកត្តាធម្មជាតិៈ

**កត្តាមនុស្ស**

- ការដាក់មងត្រី
- ការបំពុលត្រី
- ការបោកគ្រាប់បែក
- ភាពកើនឡើងនៃចំនួនទេសចរនៅក្នុងតំបន់ធ្វើអោយមានការប៉ះពាល់ដល់ការរស់នៅរស់សត្វផ្សោត ដូចជាៈ កាលណាមានទេសចរចុះទៅទស្សនាច្រើន (ការជិះទូកទស្សនាសត្វផ្សោត) ធ្វើអោយសត្វផ្សោតពិបាកក្នុងការស្វែងរកចំណី (ត្រី) ព្រោះតែការគេចវេសចេញហ្វូងមនុស្សដែលតាមទស្សនា។ ទេសចរចូលទៅទស្សនាច្រើនធ្វើអោយមានការប៉ះពាល់ទាំងបរិស្ថាន និងជីវិតរបស់សត្វផ្សោតផងដែរដោយការចោលសំរាម ឬកាកសំណលនានាចូលទៅក្នុងទឹកដែលធ្វើអោយមានជាតិពុល និងកខ្វក់ ទឹកផងដែរ។

**កត្តាធម្មជាតិ**

ការស្លាប់របស់សត្វផ្សោតដោយកត្តាធម្មជាតិនេះ គឺមានតិចតួចណាស់ដូចជាៈ

- ដោយគ្រោះទឹកជំនន់ ឬក៏គ្រោះរាំងស្ងួត
- ដោយសារកត្តាអាកាសធាតុ
- ដោយអាយុរបស់វាចាស់ ឬឈឺ

ដូចដែលបានធ្វើការរៀបរាប់ទាំងពីរកត្តាដូចខាងលើ យើងអាចធ្វើការប៉ាន់ស្មានដឹងថា មនុស្សជាកត្តាដែលធ្វើអោយមានផលប៉ះពាល់ខ្លាំងបំផុត ចំពោះភាពបាត់បង់របស់សត្វផ្សោត។

## ៨. ការអភិរក្សសត្វផ្សោតទន្លេមេគង្គ

ដោយសារសត្វផ្សោតទន្លេមេគង្គជាថនិកសត្វដ៏កំរ និងមានតិចតួចបំផុតហើយទទួលរងនូវការយាយីជីវិតពីមនុស្ស ដែលជាហេតុធ្វើអោយមានអគ្រោថយចុះជាលំដាប់នៃចំនួនពពួកថនិកសត្វដ៏កំរនេះ ហើយក៏អាចឈានទៅដល់ការដាច់ពូជនៃ សត្វផ្សោតទឹកសាបនេះពីលើផែនដីនេះទៀតផង ហេតុនេះហើយទើបបណ្តាលអោយមានការបង្កើតនូវក្រុមអ្នកអភិរក្សសត្វផ្សោតទន្លេមេគង្គនេះឡើង។

គោលបំណងនៃការបង្កើតក្រុមអ្នកអភិរក្សនេះឡើង គឺដើម្បីធ្វើការការពារកុំអោយផុតពូជ និងថែរក្សាសត្វផ្សោតប្រភេទទឹកសាបនេះអោយមាននៅលើផែនដីយើងដើម្បីអោយក្មេងៗជំនាន់ក្រោយបានស្គាល់ពីថនិកសត្វប្រភេទនេះ។

បច្ចុប្បន្ននេះ បន្ទាប់ពីក្រុមអ្នកអភិរក្សសត្វផ្សោតរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏មានការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាលឈ្មោះ **Mekong Dolphin Consevation Project (MDCP)** ហើយក៏មានការចូលរួមផងដែរពីសំណាក់អង្គការអភិរក្សសត្វព្រៃ ឈ្មោះ **WWF**។

គោលបំណងរបស់ពួកគេដែលចូលរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីទប់ស្កាត់អត្រានៃការបាត់បង់របស់សត្វផ្សោតទន្លេមេគង្គនេះដោយធ្វើការពន្យល់ណែនាំពីផលអាក្រក់ និងអត្ថប្រយោជន៏របស់សត្វផ្សោតទៅដល់ប្រជាជនដែលរស់នៅក្នុងតំបន់អោយមានការយល់ដឹងកាន់តែច្រើនឡើង។



ពីមុនប្រជាជនដែលរស់នៅក្នុងតំបន់នេះមិនមានការយល់ខ្លស់ពីផលអាក្រក់ និងអត្ថប្រយោជន៏របស់សត្វផ្សោតនេះទេ ហើយថែមទាំងមានការខឹងចំពោះការចេញច្បាប់បំរាមរបស់រាជរដ្ឋាភិបាលទៀតផង ប៉ុន្តែក្រោយពីមានការចុះទៅពន្យល់ណែនាំប្រជាពលរដ្ឋទាំងនោះដល់មូលដ្ឋាន ទើបធ្វើអោយពួកគេមានការបានយល់កាន់តែច្បាស់ហើយថែមទាំងធ្វើការចូលរួមការពារជាមួយរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងការទប់ស្កាត់ការសំលាប់សត្វផ្សោតនេះទៀតផង។ មិនត្រឹមតែមានការបំរាមមិនអោយមានការប្រើប្រាស់មងដាក់ត្រីគ្រប់ប្រភេទការបំពុលត្រី និងការបោកគ្រាប់បែកនោះទេ ហើយថែមទាំងបង្កើតអោយមានក្រុមឆ្មាំទន្លេទៀតផង (៥-៦ប៉ុស្តិ៍នៅតាមតំបន់អន្លង់នានាដែលស្ថិតនៅតាមដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា)។

## ៩. ផែនការរៀបចំ និងការអភិរក្សធនធានសត្វផ្សោតទន្លេមេគង្គនៅក្នុង ខេត្តក្រចេះ

### ៩. ១. ការបង្កើតគោលនយោបាយក្នុងការរៀបចំ និងអភិរក្សសត្វផ្សោតទន្លេមេគង្គ



ក្នុងការរៀបចំបង្កើតអោយមានគោលនយោបាយសំរាប់ការការពារសត្វផ្សោត និងការអភិរក្សទៅលើសត្វផ្សោតទន្លេមេគង្គដែលជាធនធានដ៏កំរមួយ ដើម្បីឈានទៅរកការអភិវឌ្ឍន៏តំរោងមួយដ៏ត្រឹមត្រូវ និងទទួលបានជោគជ័យ ។ គោលនយោបាយទេសចរណ៍ គឺជាត្រីវិស័យមួយដ៏ចំបងសំរាប់តំរង់ទិសដៅក្នុងការរៀបចំ និងការអភិរក្សដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានដែលកើតឡើងធ្ងន់ធ្ងរ និងជាកត្តាកំណត់នូវគោលការណ៍ណែនាំសំរាប់ការរៀបចំការអភិរក្សប្រកបដោយនិរន្តភាពយូរអង្វែងតទៅមុខ ។

ជាក់ស្តែងនៅក្នុងទឹកដីខេត្តក្រចេះ គឺជាតំបន់ទេសចរណ៍បែបអេកូធម្មជាតិ (Eco-Tourism) ដែលត្រូវការទាមទារនូវការគ្រប់គ្រងអោយបានម៉ត់ចត់បើរៀបចំខុស ដោយមិនមានគោលនយោបាយត្រឹមត្រូវនោះនឹងធ្វើអោយបាត់បង់នូវលក្ខណៈដើម ។ សព្វថ្ងៃនៅខេត្តក្រចេះ សកម្មភាពទាំងពីរនេះនៅមិនទាន់ជាដុំកំភួននៅឡើយទេ ហើយក៏មិនទាន់មានការប្រើប្រាស់ធនធានអោយបានអស់ពីលទ្ធភាពដែរ ជាហេតុធ្វើអោយធនធានទាំងនេះកំពុងតែទទួលរងនូវការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរ ។

គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺការរៀបចំនិងការអភិរក្សដែលមានគោលការណ៍ ដូចខាងក្រោមៈ

- រក្សាភាពដើម និងធ្វើការពង្រឹងតំបន់អោយមានភាពទាក់ទាញ គឺត្រូវកំនត់តំបន់អន្លង់ផ្សោតណាមួយអនុវត្តន៍អោយភ្ញៀវទៅកំសាន្ត ហើយតំបន់អន្លង់ផ្សោតដែលជាកន្លែងស្នាក់នៅរបស់វាត្រូវតែធ្វើការការពារ និងរក្សាទុកនូវទ្រទ្រង់ដើមនៃធម្មជាតិ



- លើកតំលៃធនធានដែលមានស្រាប់ កុំអោយបាត់បង់
- ជំរុញអោយមានការអភិវឌ្ឍន៏លើវិស័យទេសចរណ៍នៅតំបន់អន្លង់ផ្សោតនានាដែលស្ថិតនៅក្នុងខេត្តក្រចេះ
- ធ្វើការផ្សព្វផ្សាយជាសាធារណដល់ប្រជាជនគ្រប់ខេត្ត-ក្រុងពីធនធានដែលមាននៅក្នុងតំបន់ ( តាមរយៈ កាសែត ទស្សនាវដ្តី អ៊ីនធឺណែតខិត្តប័ណ្ណផ្សព្វផ្សាយពន្យល់នានា)
- ត្រូវផ្តល់ពណ៌មានផ្សេងៗស្តីពីធនធានដែលមាននៅក្នុងតំបន់ទៅដល់ក្រុមហ៊ុនទេសចរណ៍នានា

- បង្កើនជីវភាពប្រជាជនក្នុងតំបន់ និងធ្វើការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ (មានន័យថាប្រធានសមាគមន៍ ឬអង្គការបណ្តុះណ្តាលធនធានមនុស្សប្រចាំខេត្តក្រចេះ បង្កើតកម្មវិធីជំនាញវិជ្ជាក្នុងប្រកបរបរចិញ្ចឹមជីវិតក្នុងបរិវេនរមណីយដ្ឋានកាំពី)
- ធ្វើការបញ្ចូលពតិមានស្តីពីសក្តានុពលរបស់សត្វផ្សោតមាននៅក្នុងតំបន់អន្លង់កាំពីចូលទៅក្នុងកម្មវិធីសិក្សាចាប់ពីថ្នាក់អនុវិទ្យាល័យដល់វិទ្យាល័យ
- ធ្វើការថែទាំ និងកាត់បន្ថយនៅពេលមានភ្ញៀវកើនឡើងច្រើនអាចបង្កអោយមានគ្រោះថ្នាក់ដល់បរិស្ថានពិសេសសត្វផ្សោត ដូចជាៈ

១. បើមានទូកទេសចរណ៍ក្នុងមួយថ្ងៃមាន ១០ទូកយើងត្រវធ្វើការរៀបចំចាត់ចែងពេលវេលាអោយ ច្បាស់លាស់និងទីកន្លែងខុសៗគ្នានៅតាមតំបន់អន្លង់ផ្សោតនានា

២. ត្រូវដាក់បំរាមរាល់ចំពោះនាវា ឬទូកប្រជាជន និងទេសចរត្រូវធ្វើការពន្លត់ម៉ាស៊ីននៅឆ្លងកាត់តំបន់ដែលសត្វផ្សោតរស់នៅ ពិសេសតំបន់អន្លង់ផ្សោតតែម្តង



៣. រាជរដ្ឋាភិបាល ក៏ដូចប្រជាជនដេលរស់នៅក្នុងតំបន់ត្រូវធ្វើការសហការគ្នារាល់ពេលមានការនេសាទ ឬមានអ្វីដែលកើតឡើងខុសច្បាប់ចំពោះសត្វផ្សោត

៤. បង្កើតអោយមានក្រុមអ្នកអភិរក្សតាមដងទន្លេមេគង្គ ពិសេសតំបន់អន្លង់ផ្សោតនេះ

## ១០. ការរៀបចំគំរោងផែនអោយមានភាពទាក់ទាញនៅតំបន់អន្លង់ផ្សោតកាំពី

ដើម្បីរៀបចំគំរោងផែនការ អោយមានភាពទាក់ទាញនៅតាមតំបន់អន្លង់ផ្សោតនានា ជាពិសេស តំបន់អន្លង់ផ្សោតកាំពី គឺក្រសួងទេសចរណ៍ត្រូវតែមានគំរោងក្នុងការអភិវឌ្ឍន៏តំបន់កាំពីនេះអោយមានភាពប្រសើរឡើងថែមទៀតដូចជាៈ

- រៀបចំចរាចរណ៍អោយមានសណ្តាប់ធ្នាប់ល្អទៅតាមតំបន់កំសាន្តនិមួយៗ
- ជុសជុលផ្លូវដែលមានការខូចខាតក្នុងតំបន់រមណីយដ្ឋាននានា
- ពង្រីកផ្លូវអោយមានលក្ខណៈធំទូលាយជាងមុន ដើម្បីងាយស្រួលក្នុងការធ្វើចរាចរណ៍ទៅមក
- រៀបចំសណ្តាប់ធ្នាប់សាធារណៈ កុំអោយមានភាពរញ៉េរញ៉ៃ រួមទាំងសន្តិសុខក្នុងតំបន់រមណីយដ្ឋាន
- បង្កើតភាពងាយនៅតាមតំបន់រមណីយដ្ឋានក្នុងការទស្សនាសត្វផ្សោតរបស់ភ្ញៀវទេសចរ
- បង្កើតកន្លែងសំរាប់បង្ហាត់សត្វផ្សោតអោយមកទទួលចំនីពីភ្ញៀវទេសចរ និងចេះធ្វើសកម្មភាពផ្សេងៗដែលជាការចាប់អារម្មណ៍ពីសំណាក់ភ្ញៀវទេសចរ ។
- ប្រធានសហគមន៏ត្រូវសហការជាមួយនឹងប្រធានមន្ទីរទេសចរណ៍ បង្កើតនូវកម្មវិធីថ្មីៗ ឬសកម្មភាពសំដែងជារឿងដែលទាក់ទងនឹងសត្វផ្សោតដល់ភ្ញៀវទេសចរទស្សនាកំសាន្ត និង ធ្វើការផ្សព្វផ្សាយ អោយទូលំទូលាយពីសកម្មភាពថ្មីដែលបានបង្កើតឡើង។
- បណ្តុះគំនិតប្រជាពលរដ្ឋអោយចេះកែច្នៃផលិតផលវត្ថុអនុស្សាវរីយ៍ថ្មីៗដែលទាក់ទាញ ក្រៅពីការទស្សនាសត្វផ្សោត ការធ្វើរូបចំលាក់សត្វផ្សោត នំកាឡាន ណែមជាដើម... ។
- កែច្នៃតំបន់មួយចំនួនដែលនៅជិតតំបន់កាំពី ដូចជាកោះព្រហ្មចារី គឺជាកោះមួយដែលស្ថិតនៅជាប់នឹងអន្លង់កាំពីដែលលក្ខណៈជាធម្មជាតិទាំងស្រុងដោយមានឆ្នេរខ្សាច់សស្អាតអំណោយផលល្អ ដោយយើងកែច្នៃបន្ថែមអោយមានលក្ខណៈងាយស្រួលធ្វើការកំនត់តំបន់ងូតទឹកកំសាន្តដែលមាន សុវត្ថិភាពល្អនៅរដូវប្រាំងព្រោះយើងអាចទៅកំសាន្តបាន
- ធ្វើការផ្សព្វផ្សាយតាមអ៊ីធឺនែត ដើម្បីទាក់ទាញភ្ញៀវពីខាងក្រៅអោយបានច្រើនមកកំសាន្តនៅក្នុង ខេត្តក្រចេះ
- បង្កើតនៅភោជនីយដ្ឋាន និងសេវាកម្មផ្សេងៗដែលបំរើដល់វិស័យទេសចរណ៍ និងទីកន្លែងអង្គុយលេងអោយបានច្រើនត្រង់ចំនុចតំបន់អន្លង់កាំពី ។

# ផែនទី នៃ ភូមិកាំពី

( ឧបសម្ព័ន្ធ នៃភូមិកាំពី )

## ស្រុកក្រចេះ ខេត្តក្រចេះ



## ១១. សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវទៅលើសក្តានុពលនៃធនធានធម្មជាតិដែលមាននៅក្នុងខេត្តក្រចេះក្នុងការអភិរក្ស និងរៀបចំផែនការអោយមានភាពទាក់ទាញលើវិស័យទេសចរណ៍នៅតំបន់រមណិយដ្ឋានអន្លង់ផ្សោត (កាំពី) រួចមក យើងអាចធ្វើការសន្និដ្ឋានតំបន់នេះពោរពេញទៅដោយធនធានធម្មជាតិល្អៗជាច្រើននិងមានតំលៃតំណាងអោយវប្បធម៌ជាតិរួមមានសត្វផ្សោតក្បាលត្រឡោកដែលជាប្រភេទថនិកសត្វដ៏កំរមាននៅលើផែនដីយើងនេះណាស់កាឡានខេត្តក្រចេះ និងណែមខេត្តក្រចេះជាដើមទាំងនេះសុទ្ធតែបាន ឆ្លុះបញ្ចាំងពីធនធានធម្មជាតិ និងវប្បធម៌របស់ខ្មែរសំរាប់ជាការទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិអោយមកកំសាន្ត និងសំរាក់លំហែ។

ការរៀបចំ និងការអភិរក្សរមណីយដ្ឋានតំបន់អន្លង់ផ្សោត (កាំពី) មានសារៈសំខាន់ណាស់ចំពោះតំបន់នេះមុននឹងឈានទៅដល់ការអភិវឌ្ឍន៏វិស័យទេសចរណ៏មួយប្រកបដោយប្រសិទ្ធិភាពខ្ពស់នឹងមាននិរន្តភាពយូរអង្វែង។ សកម្មភាពទាំងពីរខាងលើនៅតំបន់នេះមានកំរិតទាបនៅឡើយ ទោះបីមានគំរោងផែនការល្អៗក៏ដោយ តែបញ្ហាប្រឈមមុខសំខាន់បំផុត គឺពុំមានថវិកាគ្រប់គ្រាន់ក្នុងការរៀបចំ ព្រមទាំងពុំមានការយកចិត្តទុកដាក់អស់ពីចិត្តពីថ្លើមពីសំណាក់រាជរដ្ឋាភិបាលយើង ដោយខ្វះខាតនូវគោលនយោបាយទេសចរណ៍ និងច្បាប់បទដ្ឋានស្តីពីតំបន់នេះ។ ស្ថាប័នទេសចរណ៏ក្នុងខេត្តក៏ដូចច្នោះដែរ ហាក់បីដូចជាពុំស៊ីសង្វាក់គ្នាក្នុងការអនុវត្តការងារទាល់តែសោះ។ ការរៀបចំ និងការអភិរក្សនៅកកស្ទះពុំមានដំណោះស្រាយ ជាហេតុពុំអាចទាក់ទាញអ្នកទេសចរជាតិ និងអន្តរជាតិមកទស្សនានៅតំបន់នេះ។ ជាងនេះទៅទៀត គ្រប់វិស័យផ្សេងៗដែលមានការពាក់ព័ន្ធនឹងទេសចរណ៏នៅតំបន់នេះក៏នៅមានកំរិតទាបដែរ ដែលបណ្តាលអោយជីវភាពប្រជាជននៅក្នុងតំបន់មានការខ្វះខាតគួរអោយកត់សំគាល់។

សរុបសេចក្តីមកយើងឃើញថា តំបន់រមណីយដ្ឋានអន្លង់ផ្សោត (កាំពី) មានភាពទន់ខ្សោយច្រើនទាំងវិស័យសេដ្ឋកិច្ច និងវិស័យទេសចរណ៏ ព្រមទាំងច្បាប់គ្រប់គ្រង់ និងអភិរក្ស ដូច្នេះត្រូវទាមទារអោយមាន ការជួយឧបត្ថម្ភគាំទ្រចេញពីផ្នែកស្មារតី សំភារៈ ធនធានមនុស្ស ថវិកា ការគ្របលគ្រងរៀបចំ ពីស្ថាប័នជាតិ និងអន្តរជាតិដើម្បីប្រែក្លាយតំបន់នេះឈានទៅរកការអភិវឌ្ឍន៏មួយដែលមានការរីកចំរើន និងប្រកបដោយនិរន្តភាព ដូចជាតំបន់ផ្សេងៗទៀតដែលបានអភិវឌ្ឍន៏រួចកន្លងមក ហើយទទួលបានជោគជ័យនៅក្នុងប្រទេសយើងមានតំបន់អង្គរជាដើម។

## ១២. អនុសាសន៍

តាមរយ:ការសិក្សាស្រាវជ្រាវខាងលើនេះ អាចអោយយើងសន្និដ្ឋានបានថា: អន្លង់ផ្សោតពីនៅមានចំនុច ខ្វះខាតជាច្រើនទាំងការអភិវឌ្ឍន៍ និងការអភិរក្សទៅលើសត្វផ្សោត ព្រមទាំងវិស័យទេសចរណ៍ដែលមាននៅក្នុងតំបន់។ ដូច្នេះគំនិតរបស់ក្រុមនិស្សិតយើងខ្ញុំមានយោបល់ថា:

- ត្រូវដាក់បំរាមរាល់ចំពោះនាវា ឬទូកប្រជាជន និងទេសចរត្រូវធ្វើការពន្លត់ម៉ាស៊ីននៅឆ្លងកាត់តំបន់ដែលសត្វផ្សោតរស់នៅ ពិសេសគឺតំបន់អន្លង់ផ្សោតតែម្តង
- រាជរដ្ឋាភិបាលក៏ដូចប្រជាជនដែលរស់នៅក្នុង តំបន់ត្រូវធ្វើការសហការគ្នារាល់ពេលមានការនេសាទ ឬមានអ្វីដែលកើតឡើងខុសច្បាប់ចំពោះសត្វផ្សោត
- បង្កើតអោយមានក្រុមអ្នកអភិរក្សតាមដងទន្លេមេគង្គ ពិសេសតំបន់អន្លង់ផ្សោតនេះធ្វើយ៉ាងណា អោយមានភាពតឹងរឹង និងមានសណ្តាប់ធ្នាប់ល្អ
- សហគមន៍គួរតែសហការណ៍ជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រសួងដែលពាក់ព័ន្ធដើម្បីស្វែងរកមូលនិធិសំរាប់ទិញឧបករណ៍ទំនើបៗមកបំពាក់ទៅលើសត្វផ្សោតក្នុងការតាមដានរាល់សកម្មភាពរស់នៅរបស់សត្វផ្សោត
- បង្កើតបន្ថែមកំលាំងឆ្មាំនៅពេលចុះល្បាតតាមតំបន់អន្លង់ ដើម្បីធ្វើការការពារសត្វផ្សោត និងផ្តល់ជាអាវុធក្នុងការពារខ្លួននៅពេលបំពេញភារ:កិច្ច
- បង្កើតអោយមានបសុពេទ្យដើម្បីព្យាបាលសត្វផ្សោតពេលវាឈឺ ឬពេលវាកើតកូន (នៅពេលដែលបំពាក់ឧបករណ៍ទៅលើវាបានសម្រេច)
- ដាក់បំរាមចំពោះប្រជាជនដែលរស់នៅក្នុងតំបន់មិនអោយបង្ហូរកាកសំណល់ផ្សេងៗចូលទៅក្នុងទន្លេ ពីព្រោះវាអាចធ្វើអោយបរិស្ថានកខ្វក់ធ្វើអោយប៉ះពាល់ដល់ការរស់នៅរបស់សត្វផ្សោត និងទេសចរ
- គួរតែបង្កើតទីកន្លែងថ្មីដោយធ្វើឡើងនៅលើគោកដោយធ្វើជាអាងធំមួយសំរាប់បង្ហាត់សត្វផ្សោតអោយមានលក្ខណ:ផ្សាំជាមួយមនុស្ស និងបង្កើតអោយមានការសម្តែងជាល្បុតខ្លីៗដែលសម្តែង ដោយសត្វផ្សោតសំរាប់ធ្វើការលក់សំបុត្រចូលទស្សនា
- ធ្វើការផ្សព្វផ្សាយតាមអ៊ីធឺណែត ដើម្បីទាក់ទាញភ្ញៀវពីខាងក្រៅអោយបានច្រើនមកកំសាន្តនៅក្នុងខេត្តក្រចេះ
- បង្កើតនៅភោជនីយដ្ឋាន និង សេវាកម្មផ្សេងៗដែលបំរើដល់វិស័យទេសចរណ៍ និង ទីកន្លែងអង្គុយលេងអោយបានច្រើនត្រង់ចំនុចតំបន់អន្លង់កាំពី ។

- កែច្នៃតំបន់មួយចំនួនដែលនៅជិតតំបន់កាំពី ដូចជាកោះព្រហ្មចារី គឺជាកោះមួយដែលស្ថិតនៅជាប់នឹងអន្លង់កាំពីដែលលក្ខណៈជាធម្មជាតិទាំងស្រុងដោយមានឆ្នេរខ្សាច់សស្អាតអំណោយផលល្អ ដោយយើងកែច្នៃបន្ថែមអោយមានលក្ខណៈងាយស្រួល ធ្វើការកំនត់តំបន់ងូតទឹកកំសាន្តដែលមាន សុវត្ថិភាពល្អនៅរដូវប្រាំងព្រោះយើងអាចទៅកំសាន្តបាន ។
- ធ្វើការជុសជុលផ្លូវ និងពង្រីកផ្លូវអោយមានលក្ខណៈធំទូលាយដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងជួយសំរួលដល់ការធ្វើដំណើររបស់ទេសចរ
- អាជ្ញាធរដែនដីត្រូវពង្រឹងសន្តិសុខ និងសុវត្ថិភាពនៅក្នុងតំបន់ដើម្បីអោយភ្ញៀវទេសចរមានភាពកក់ក្តៅនៅពេលមកលេងក្នុងតំបន់កាំពីនេះ ។

## ឯកសារស្រាវជ្រាវ

1. Mekong Dolphin Conservation Project (MDCP) Website: www.mekongdolphin.com

2. BAH. 5.0142 ( ការរៀបចំ និងការអភិរក្សតំបន់ទេសចរណ៍វប្បធម៌ប្រាសាទបន្ទាយឆ្មារ) ២០០១-២០០៥ សារណាទំព័រ ៤៩-៥៨

3. ការចុះទៅ Research ពិតិមានផ្ទាល់នៅខេត្តក្រចេះរបស់ក្រុមនិស្សិតនៃសាកលវិទ្យាល័យ ន័រតុន ផ្នែកគ្រន់គ្រងសណ្ឋាគារ និង ទេសចរណ៍ ឆ្នាំទី៣ ( ចាប់ពីថ្ងៃទី ២៨-៣០ ខែមករា ឆ្នាំ ២០០៧)

4. ការសម្ភាសន៍ដោយផ្ទាល់ជាមួយលោក **ទុយ សុវណ្ណ** ( ប្រធានខាងផ្នែកអភិរក្សសត្វផ្សោតខេត្តក្រចេះ)